ទីស្តីការក្រសួងយុត្តិធម៌
លេខ ០២ អក-សរច-៩៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សារាចរ</u>

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបចក</u>**

លោកប្រធានតុលាការ ខេត្ត ក្រុង
លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ ខេត្ត ក្រុង

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** ករណីអនីតិជនអាយុក្រោម ១៨ឆ្នាំ ។

ក្រោយពីក្រសួងបានធ្វើសារទូលេខ ០៣ ស.ទ ៩៥ ចុះថ្ងៃទី១៣.១.៩៥ ផ្ញើមកតុលាការនឹងអយ្យការគ្រប់ខេត្ត ក្រុង ឱ្យធ្វើបញ្ជីស្រង់ចំនួនពិរុទ្ធជននិងទណ្ឌិតដែលមានអាយុតិចជាង ១៨ឆ្នាំ នោះក្រសួងបានពិនិត្យឃើញថាចំនួនអនីតិជនអាយុក្រោម ១៨ឆ្នាំ នៅតាមមន្ទីរឃុំឃាំងនិងមន្ទីរពន្ធនាគារ ខេត្តក្រុងមានការកើនឡើងច្រើន ។ អាស្រ័យហេតុនេះសូមលោកព្រះរាជអាជ្ញានិងលោកចៅក្រមស៊ើបអង្កេតយកចិត្តទុកដាក់អនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រង់មាត្រា ១៩ កថាខណ្ឌទី ៥ ដែលបានចែងថាអតីតិជនអាយុតិចជាង១៣ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ អនីតិជនដែលមានអាយុ ១៣ឆ្នាំ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី១ខែទេ ។ រយៈពេលនេះអាចទ្វេឡើងជាពីរបើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

សូមអស់លោកអនុវត្តតាមច្បាប់ឱ្យបានហ្មត់ចត់និងត្រឹមត្រូវតទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្កួន**